CHAKTO

# CHAKTO CHOREOGRAPHY WRITING:
# PANEL DISCUSSION & PITCHING SESSION

AMBASSADE DE FRANCE AU CAMBODGE
Liberté Égalité Fraternité

INSTITUT FRANÇAIS Cambodge

សិល្បៈខ្មែរអមតៈ CAMBODIAN LIVING ARTS

MEKONG CULTURAL HUB

# ទិដ្ឋភាពទូទៅអំពីគម្រោង
# សរសេរដំឡើងស្នាដៃរបាំនៃគម្រោង «ចតុ»

គម្រោងនេះជាផ្នែកមួយនៃគម្រោងចតុដែលផ្តល់មូលនិធិដោយវិទ្យាស្ថានបារាំងនៅកម្ពុជា ដើម្បីលើកស្ទួយឧស្សាហកម្មច្នៃប្រតិដ្ឋនិងវប្បធម៌នៅកម្ពុជា។ ដោយផ្តោតជាពិសេសលើការសរសេរ គម្រោងនេះមានគោលបំណងផ្តល់ឱកាសដល់អ្នកមានទេពកោសល្យជាជនជាតិកម្ពុជាដែលទើបប្រឡូកនៅក្នុងវិស័យ៤ (ភាពយន្ត សៀវភៅ របាំនិងតន្ត្រី) ដោយសហការជាដៃគូជាមួយផលិតកម្មភាពយន្ត Anti-Archive, អង្គការស៊ីប៉ា, អង្គការសិល្បៈខ្មែរអមតៈ និងកងចក្រភីកឈ័រ។

គម្រោងសរសេរដំឡើងស្នាដៃរបាំនេះមានគោលបំណងពង្រឹងនូវគុណភាពស្នាដៃនៃសហគមន៍របាំកម្ពុជា តាមរយៈការពង្រឹងជំនាញសរសេររបស់អ្នកសរសេរដំឡើងស្នាដៃរបាំទាំងពីរជំនាន់ ពោលគឺ អ្នកសរសេរដំឡើងស្នាដៃរបាំរៀមច្បង និងវ័យក្មេង។

គម្រោងនេះនាំមកជូននូវសិក្ខាសាលាចំនួនពីរ រួមមាន៖

១. ថ្នាក់ Masterclass ( ថ្ងៃទី ១១ ដល់ ១៦ ខែកុម្ភៈ ឆ្នាំ២០២៥ )៖ អ្នកសរសេរដំឡើងស្នាដៃរបាំចំនួន៥រូបនឹងត្រូវបានជ្រើសរើសតាមរយៈពាក្យស្នើសុំ ដើម្បីចូលរួមសិក្សាថ្នាក់ Masterclass ដឹកនាំដោយលោកហ្វូអាដ់ ប៊ូស៊ូហ្វ (Fouad Boussouf) នាយកនៃមជ្ឈមណ្ឌល Le Phare CCN Du Havre និងជាគ្រូរបាំសហសម័យដ៏ល្បីនៅប្រទេសបារាំង។ ថ្នាក់សិក្សានេះនឹងផ្តោតលើការដុះខាត់ជំនាញសរសេរដំឡើងស្នាដៃរបាំរបស់អ្នកចូលរួម និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការបង្កើតគំនិត និងបង្កើតស្នាដៃរបាំប្រកបដោយភាពច្នៃប្រតិដ្ឋ។

   អ្នកដំឡើងស្នាដៃរបាំចំនួនបីរូបនឹងត្រូវជ្រើសរើសឱ្យធ្វើការជាជំនួយការគ្រូបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលាទីពីរ ហើយពួកគាត់នឹងបន្តធ្វើការជាអ្នកប្រឹក្សាជំនាញសិល្បៈរហូតដល់ខែតុលា សម្រាប់អ្នកទទួលជ័យលាភីចំនួនប្រាំរូបដែលទទួលបានមូលនិធិអភិវឌ្ឍស្នាដៃបន្ត។

២. ការបណ្តុះបណ្តាលអ្នកសរសេរដំឡើងរបាំរ៉ាយក្មេង (ថ្ងៃទី២១-២៣ និង ថ្ងៃទី២៨-៣០ ខែមីនា ឆ្នាំ ២០២៥) ដឹកនាំដោយលោកស្រី អេម៉ានុយអែល ភួន។ គោលបំណងសំខាន់នៃការបណ្តុះបណ្តាលអ្នកសរសេរដំឡើងរបាំរ៉ាយក្មេងនេះគឺដើម្បីចាក់គ្រឹះមូលដ្ឋានក្នុងការសរសេរដំឡើងស្នាដៃរបាំនិងផ្តល់ឱកាសឱ្យអ្នកសរសេរដំឡើងស្នាដៃរបាំរ៉ាយក្មេងបានអនុវត្តផ្ទាល់តែម្តង។

សិក្ខាសាលាចែកចេញជាបីដំណាក់កាលសំខាន់ៗទៅតាមពេលវេលាដូចខាងក្រោម៖

**ដំណាក់កាលទី១ – ការបណ្តុះបណ្តាល៖** សិក្ខាកាមនឹងចូលរួមការបណ្តុះបណ្តាលពីថ្ងៃ២១-២៣ និងពីថ្ងៃ២៨-៣០មីនា២០២៥ដែលផ្តោតលើមូលដ្ឋានគ្រឹះនៃការសរសេរដំឡើងស្នាដៃរបាំ។ការបណ្តុះបណ្តាលនេះរួមមានទាំងសកម្មភាពនៅក្នុងថ្នាក់ការដាក់ការងារឱ្យអាននិងការឱ្យមើលវីដេអូនៅមុននិងអំឡុងពេលនៃការបណ្តុះបណ្តាល។

**ដំណាក់កាលទី២ – ការបង្ហាញស្នាដៃដំឡើង៖** ក្រោយការបណ្តុះបណ្តាល សិក្ខាកាមនឹងមានឱកាសទទួលបានការណែនាំដ៏មានន័យលើស្នាដៃដំឡើងរបាំរបស់ពួកគេ។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥ ក្រុមគណៈកម្មការជំនាញថ្នាក់ជាតិនិងថ្នាក់តំបន់នឹងផ្តល់មតិយោបល់ផ្សេងៗនៅពេលសិក្ខាកាមឡើងបង្ហាញគម្រោងរៀងៗខ្លួន។ ផ្អែកលើការផ្តល់មតិយោបល់របស់គណៈកម្មការ អ្នកសរសេរដំឡើងស្នាដៃរបាំរ៉ាយក្មេងរហូតដល់៥រូបនឹងត្រូវជ្រើសរើសនិងទទួលបានកញ្ចប់ថវិកា ដើម្បីនាំយកស្នាដៃខ្នាតខ្លីទាំងនេះទៅដំណើរការផលិតចេញជាស្នាដៃសិល្បៈពេញលេញដែលមានរយៈពេលពី ២០ ទៅ ២៥ នាទី។

**ដំណាក់កាលទី៣ – ការសម្តែង៖** សិក្ខាកាមដែលទទួលបានថវិកាដើម្បីដំណើរការផលិតស្នាដៃ នឹងបង្ហាញស្នាដៃរបស់ពួកគេជាសាធារណៈនៅថ្ងៃទី ០៣ និងទី ០៤ ខែតុលា ឆ្នាំ២០២៥។

# Overview of Chakto Choregraphy Writing Project

This project is part of an ongoing Chakto project supported by Institut français du Cambodge to galvanize the cultural and creative industries in Cambodia. With a specific focus on writing, it aims at benefiting emerging Cambodian talents in four specific cultural sectors (cinema, books, dance and music), in partnership with Anti-Archive, Sipar, Cambodian Living Arts and Kongchak Pictures.

This choreography writing project aims to strengthen Cambodia's dance community by enhancing choreography writing skills across two different generations of choreographers—senior and emerging/junior.

This project consists of two distinct workshops:

1. A Masterclass (February 11th-16th,2025): Five senior choreographers will be selected through an open call to engage in an intensive masterclass led by Mr. Fouad Boussouf, director of Le Phare CCN Du Havre, and a renowned French contemporary dance mentor. The Masterclass focuses on refining participants' choreography writing skills and enhancing their ability to conceptualize and articulate innovative dance works.

   Three senior choreographers will be invited to serve as assistant mentors in Workshop 2 and will continue to act as artistic advisors for the five selected grantees throughout the project until October.

2. Training for the Emerging Choreographers (March 21–23 and March 28–30, 2025) conducted by Emmanuele Phuon. The primary goal of the Training for the Emerging Choreographers is to establish foundational knowledge in choreography writing and provide hand-on experiences to Cambodian junior choreographers through an intensive workshop.

   There are three key stages and timelines in this workshop 2:

   **Stage 1- Training Sessions**: The 10 selected participants will attend the training sessions scheduled for March 21–23 and March 28–30, 2025, focusing on fundamental knowledge in choreography writing. The sessions will include in-class activities, assigned readings, and videos for preparation both before and during the training.

   **Stage 2- Pitching Session**: After completing the training, participants will have the chance to receive meaningful feedback on their choreographic work. On April 30, 2025, a panel of regional jury will offer feedback as they engage with the participants' pitching presentations. Based on this feedback, (up to) five emerging choreographers will be selected to receive a small grant to further develop their short choreographic works into work-in-progress artistic productions.

   **Stage 3 – Public Performance**: The choreographers awarded the grant to produce a work-in-progress will present their work publicly on October 03rd- 04th, 2025.

## Agenda
## Chakto Choreography Writing:
## Panel Discussion & Pitching Session

| Part I: Panel Discussion on "Bridging Horizons: Unlocking Opportunities for Southeast Asian Artists and Cultural Practitioners" | |
|---|---|
| 2.00 PM-2.45PM | Panel Discussion |
| 2.45 PM - 3.00 PM | Q&A with the Audience |
| **Part II: Pitching and Certificate Presentation** | |
| 3.20 PM - 3.30 PM | Mentors' Remark by Emmanuèle Phuon & Fouad Boussouf |
| 3.30 PM- 5.30PM | 10 Junior Choreographers Present Their Works |
| 5.30 PM - 5.50PM | Contemporary Dance Showcase "Blindfold" |
| 5.50 PM - 6.05 PM | Grants Award Announcement |
| 6.05 PM - 6:25 PM | Certificate Presentation |
| 06:25 PM - 6:30 PM | Closing Remarks |

# ទិដ្ឋភាពទូទៅនៃវេទិកាពិភាក្សា៖
# «ស្ពានសិល្បៈ-វប្បធម៌៖ ការបើកឱកាសផ្សេងៗ សម្រាប់សិល្បករ និងប្រតិបត្តិករវប្បធម៌ក្នុងតំបន់អាស៊ី»

## ទិដ្ឋភាពទូទៅនៃវេទិកាពិភាក្សា

កម្មវិធី "ស្ពានសិល្បៈ-វប្បធម៌៖ ការបើកឱកាសផ្សេងៗសម្រាប់សិល្បករនិងប្រតិបត្តិករវប្បធម៌ក្នុងតំបន់អាស៊ី" មានបំណង ភ្ជាប់ទំនាក់ទំនង (ឡើងវិញ) រវាងសិល្បៈទស្សនីយភាពកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី តាមរយៈកិច្ចសហការប្រកបដោយនិរន្តរភាពនៃគម្រោងពាក់ព័ន្ធនានា ។ ដោយមានការចូលរួមពីវាគ្មិនដូចជា សាសាភីន ស៊ីរីវ៉ាន់នីជ មកពីប៊ីផាមនៃប្រទេសថៃឡង់ដ៍, វ៉ាទ្រីអានីនឌីយ៉ាយ៉ាតទី មកពីមហោស្រពរបាំឥណ្ឌូណេស៊ីនៃប្រទេសឥណ្ឌូណេស៊ី, និង រ៉េរ៉េ មកពីមូលនិធិសិល្បៈយើងរួមគ្នានៃតៃវ៉ាន់ កិច្ចពិភាក្សានេះនឹងស្វែងរកមើល ថាតើមានឱកាសអ្វីខ្លះដែលវេទិការបស់ពួកគេអាចផ្តល់ឱ្យបាន ហើយស្វែងរកមើល ថាតើប្រតិបត្តិករវប្បធម៌និងសិល្បករកម្ពុជា អាចចូលរួមជាមួយអ្នកផ្សេងទៀតក្នុងតំបន់យ៉ាងដូចម្តេច? វាគ្មិនម្នាក់ៗនឹងធ្វើបទបង្ហាញអំពីវេទិកាដែលមានលក្ខណៈពិសេសប្លែករបស់ពួកគេ ដូចជា ប៊ីផាម (Bangkok International Performing Arts Meetings BIPAM), មហោស្រពរបាំឥណ្ឌូនេស៊ី (Indonesian Dance Festival - IDF) និងមូលនិធិសិល្បៈយើងរួមគ្នា (We Art Together Foundation) ព្រមទាំងឱកាសផ្សេងៗដែលមាននៅក្នុងវេទិកាទាំងនោះ ។

សំណួរគន្លឹះដែលនឹងលើកមកចោទសួរដើម្បីស្វែងរកឱកាសទាំងនោះ រួមមាន៖

- តើវេទិកានៅក្នុងតំបន់អាស៊ីមានឱកាសអ្វីខ្លះសម្រាប់សិល្បករកម្ពុជា?
- តើសិល្បករកម្ពុជាអាចទទួលបានព័ត៌មាននិងអាចចូលរួមបានដោយរបៀបណា?
- តើធ្វើយ៉ាងណាដើម្បីឱ្យកិច្ចសហការរវាងសិល្បករកម្ពុជានិងសិល្បករក្នុងតំបន់ អាចធ្វើឱ្យមានកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ថ្មីមួយហើយប្រកបដោយនិរន្តរភាព?
- តើមានចំណុចអ្វីខ្លះដែលសិល្បករកម្ពុជាគួរតែធ្វើ ដើម្បីចូលរួមចំណែកបង្កើតឱ្យមានកិច្ចសហការនោះនិងប្រកបដោយវឌ្ឍភាពទាំងអស់គ្នា?

សំណួរគោលទាំងនេះ នឹងជួយនាំឱ្យមានការពិភាក្សាទៅលើ ការរកវិធីដើម្បីឱ្យវេទិកាកំពុងមានក្នុងតំបន់អាស៊ី និងសហគមន៍សិល្បៈទស្សនីយភាពកម្ពុជា អាចបង្កើតឱ្យមានទំនាក់ទំនងប្រកបដោយអត្ថន័យមួយ ពោលគឺការជំរុញឱ្យកិច្ចសហការ, បរិយាបន្ន ក៏ដូចជាការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក កើតមានឡើង ។

# Panel Discussion on "Bridging Horizons: Unlocking Opportunities for Southeast Asian Artists and Cultural Practitioners"

## Panel Discussion Overview:

"Bridging Horizons: Unlocking Opportunities for Asian Artists and Cultural Practitioners" aims to (re)connect Cambodia's performing arts scene with the broader Asian region through sustainable, contextually relevant collaborations. Featuring Sasapin Siriwanij (Bangkok International Performing Arts Meetings_BIPAM, Thailand), Ratri Anindyajati (Indonesian Dance Festival, Indonesia_IDF), and Wei Wei (We ART Together Foundation, Taiwan), this session will explore the opportunities these platforms offer and how Cambodian artists and cultural practitioners can engage with their regional peers. Each panelist will present the unique platform they represent—BIPAM, IDF, and We ART Together—and the opportunities they offer. Key questions we will explore include:

- What opportunities are available to Cambodian artists through regional platforms in Asia?
- How can Cambodian artists access and engage with these opportunities?
- How can collaboration between Cambodian artists and regional peers lead to new and sustainable exchanges?
- What steps can Cambodian artists take to contribute to and thrive in these collaborations?

These questions will guide a discussion on how existing platforms in Asia and the Cambodian performing arts community can build meaningful connections—fostering collaboration, inclusivity, and reciprocal exchange.

## Panelist



Ratri Hapsari Anindyajati

រ៉ាទ្រី ហាបសារី អានីនឌីយ៉ាយ៉ាតទី  គឺជាផលិតករឯករាជ្យម្នាក់ ធ្វើការជាមួយសិល្បករឥណ្ឌូណេស៊ីនិងសិល្បករអន្តរជាតិទូទាំង សកលលោក ។ បច្ចុប្បន្ន គាត់គឺជានាយិកាមហោស្រពរបាំឥណ្ឌូណេស៊ី ដែលជាមហោស្រពរបាំសហសម័យមួយ រៀបចំឡើងរៀងរាល់ពីរឆ្នាំម្តង ។ មហោស្រពនេះ បានបង្កើត ឡើងតាំងពីឆ្នាំ ១៩៩២ មកម្លេះ ហើយវាក៏ជាមហោស្រពដែលមានអាយុច្រើនជាងមហោស្រពនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ រួមគ្នាជាមួយនឹងសិល្បករប្រចាំក្រុងអិលអេ (LA) ម្នាក់ឈ្មោះ អិដហ្គឺរ អាសស៊ីណូ (Edgar Arceneaux) គាត់បានបង្កើត រ៉ារ៉ារ៉ា ជាក្រុមហ៊ុនផលិតកម្មទម្រង់ចម្រុះ ដែលមានក្រុមសិល្បៈអន្តរជាតិនានាដូចជាសិល្បករ អ្នករចនា និងអ្នកសម្តែង។ គម្រោងរបស់ រ៉ាទ្រី មានដូចជា របាំ, ល្ខោន, មហោស្រពសិល្បៈ ពិព័រណ៍ និងភាពយន្តឯករាជ្យ ។ ឆន្ទៈរបស់គាត់គឺចង់ពាំនាំការសម្តែងរបស់ឥណ្ឌូណេស៊ីទៅកាន់ពិភពលោកក៏ដូចជាការចែករំលែកសាច់រឿងនិងការផលិតស្នាដៃដែលបង្ហាញពីមនុស្សជាតិនិងអត្តសញ្ញាណតាមរយៈភាពផ្សេងៗគ្នានៃវប្បធម៌ ។

ទំហំការងាររបស់គាត់នៅក្នុងមហោស្រពរបាំឥណ្ឌូណេស៊ីក្រៅពីការរៀបចំនិងការបង្កើតកម្មវិធីការងារមួយភាគធំរបស់ រ៉ាទ្រី មានដូចជា ការផ្តត់ផ្តង់ធនធាន ការផ្តល់ជំនួយការផ្សេងៗ និង ការផ្តល់រចនាសម្ព័ន្ធ ក្នុងការបង្កើតស្នាដៃរបាំសហសម័យដោយអ្នកដំឡើងស្នាដៃឥណ្ឌូណេស៊ី និង ការងារតស៊ូមតិ ឱ្យមានគម្រោងអភិវឌ្ឍអាជីពសម្រាប់ផលិតករឥណ្ឌូណេស៊ីវ័យក្មេង ។ រ៉ាទ្រី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រនយោបាយពីសាកលវិទ្យាល័យកាតូលិកប៉ារ៉ាហ្យ៉ាងអាន់ (Parahyangan Catholic University) ក្នុងទីក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី និង ថ្នាក់អនុបណ្ឌិតវិចិត្រសិល្បៈផ្នែកគ្រប់គ្រង និងការផលិតប្រកដោយភាពច្នៃប្រតិដ្ឋ ពីដេប៉ាតឺម៉ង់ល្ខោននៃវិទ្យាស្ថានកាលីហ្វនីញ៉ាសិល្បៈ (ក្រុងឡូសអិនជឺឡិស សហរដ្ឋអាមេរិក)។

## Ratri Hapsari Anindyajati

Ratri Hapsari Anindyajati is an Independent Producer working with both Indonesian and international artists globally. She currently sits as Director for the Indonesian Dance Festival (IDF), Jakarta's biennial international contemporary dance festival held since 1992 and is the longest standing festival of its kind in Southeast Asia. With an LA based artist Edgar Arceneaux, she co-founded Rarara!, an interdisciplinary production company consisting of an international ensemble of artists, designers and performers. Ratri's projects include dance, theater, arts festivals, exhibitions and independent films and her passion lies in bringing Indonesian performance to the globe as well as storytelling and producing works which explore humanity and identity through diversity of cultures.

Through the IDF , aside from curating and programming, a large part of her efforts include providing resources, support and structures for creations of new contemporary dance works by Indonesian choreographers as well as advocating for career development for young Indonesian producers. Ratri holds a Bachelors in Political Science from Parahyangan Catholic University (Bandung, Indonesia) and a Master of Fine Arts in Creative Producing and Management from the Theater Department from California Institute of the Arts (Los Angeles, USA).

**Panelist**



**Sasapin Siriwanij**

សាសាភីន ស៊ីរីវ៉ាន់នីជ គឺជាផលិតករសិល្បៈទស្សនីយភាព អ្នករៀបចំការបង្ហាញសិល្បៈ និងសិល្បករផង ប្រចាំនៅទីក្រុងបាងកក ។ គាត់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិតផ្នែកភាសាអង់គ្លេសពីមហាវិទ្យាល័យសិល្បៈនៃសាកលវិទ្យាល័យជូឡាឡុងកន។អស់រយៈកាលជាងមួយទសវត្សរ៍មកនេះសាសាភីនបានបង្កើតស្នាដៃល្អៗជាច្រើននៅរោងល្ខោនប៊ីហ្វ្លរ (**B-Floor Theater**) ដោយបំពេញការងារជាសិល្បករសម្តែងផង អ្នកដឹកនាំផង និងផលិតករផង ។ ការងាររបស់គាត់ទាក់ទងយ៉ាងខ្លាំងទៅនឹងការរិះគន់សង្គម ការផ្តល់សិទ្ធិអំណាចឱ្យខ្លួនឯង និងការអភិវឌ្ឍសង្គម។តាំងពីឆ្នាំ២០១៨មក សាសាភីន បានក្លាយជាអ្នកដឹកនាំសិល្បៈរបស់កម្មវិធីជំនួបសិល្បៈទស្សនីយភាពអន្តរជាតិបាងកក ហៅកាត់ថា ប៊ីផាម (**BIPAM**) ។ គាត់ក៏បានចូលរួមស្ថាបនា ក្រុមផលិតករនៃបណ្តាញសិល្បៈទស្សនីយភាពថៃដែលហៅកាត់ថា ផតភែន (**POTPAN**) ក្នុងជំហរដើម្បីអភិវឌ្ឍសិល្បៈសហគមន៍ ។ ក្រៅពីមានតួនាទីជាអ្នកដឹកនាំ សាសាភីន ក៏ជាសិល្បករល្ខោនឯករាជ្យមួយរូបនិងជាអ្នកផលិតកម្មវិធីទស្សនាចរណ៍អន្តរជាតិដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយក្រុមសិល្បៈ ហ្វរតជៀតធ័រ អេន វីឆាយា អាតាម៉ាត (**For What Theatre and Wichaya Artamat**) ។

**ប៊ីផាម Bangkok International Performing Arts Meeting (BIPAM)**

តាំងពីកម្មវិធីជំនួបសិល្បៈទស្សនីយភាពអន្តរជាតិបាងកក ដែលជាកម្មវិធីជួបជុំនិងផ្លាស់ប្តូរសម្រាប់វិស័យសិល្បៈទស្សនីយភាពនៃតំបន់អាស៊ីអាគ្នេយ៍ បានចាប់ផ្តើមនៅក្នុងឆ្នាំ ២០១៧ មក កម្មវិធីនេះមានការរីកចម្រើនលូតលាស់រហូតក្លាយទៅជា ស្ថាប័នផ្តល់សេវាគ្រប់គ្រងសិល្បៈទស្សនីយភាព មួយនៅក្នុងទីក្រុងបាងកក ។ ប៊ីផាម បានកកើតឡើង ដោយអ្នកគ្រប់គ្រងសិល្បៈមួយក្រុម ជាមួយនឹងទស្សនវិស័យមួយដែលចង់ឱ្យ ប៊ីផាម ក្លាយជាច្រកទ្វារមួយសម្រាប់ពិភពលោកឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីបរិបទនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាតំបន់ពោរពេញទៅដោយសិល្បៈទស្សនីយភាពចម្រុះដ៏សម្បូរបែប មានការរីកចម្រើនឥតឈប់ឈរ និងជាកន្លែងសម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្នា រវាងប្រតិបត្តិករសិល្បៈទស្សនីយភាពរបស់បណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈវេទិកាបង្ហាញសិល្បៈទស្សនីយភាពអន្តរជាតិ។ លើសពីនេះទៀត ប៊ីផាម ក៏ជួយពង្រឹងសមត្ថភាពរបស់ប្រតិបត្តិករសិល្បៈក្នុងសហគមន៍តាមរយៈគំនិតផ្តើមផ្ទាល់របស់ខ្លួនដូចជា គម្រោងកិច្ចសហការរវាងអង្គការសិល្បៈជាតិនិងអន្តរជាតិ និងតាមរយៈគម្រោងផ្តល់សេវាកម្មនានានៃការគ្រប់គ្រងសិល្បៈ ។

## Sasapin Siriwanij

Sasapin Siriwanij is a Bangkok-based performing arts producer, curator, and artist. She holds both a Bachelor's and Master's degree in English from the Faculty of Arts at Chulalongkorn University. For over a decade, Sasapin has built a distinguished career at B-Floor Theatre as a performer, director, and producer. Her work is deeply rooted in social critique, personal empowerment, and societal transformation. Since 2018, Sasapin has been the Artistic Director of the Bangkok International Performing Arts Meeting (BIPAM). She also co-founded the Producers of Thai Performing Arts Network (POTPAN), reinforcing her commitment to the development of the local arts scene. In addition to her leadership roles, Sasapin is an independent theatre artist and international touring producer, collaborating extensively with For What Theatre and Wichaya Artamat.

**Bangkok International Performing Arts Meeting**

Beginning in 2017 as the Bangkok International Performing Arts Meeting, Southeast Asia's performing arts gathering and exchange platform, BIPAM has grown to become a performing arts management service organization based in Bangkok. BIPAM was founded by an arts manager collective with a vision to become the gateway for the world to take a step deeper into the various contexts of Southeast Asia where rich diversity in performing arts is ever-thriving, connecting Southeast Asian performing arts professionals with the international performing arts scenes. Moreover, BIPAM works to enhance the competence of local professionals through BIPAM's own initiatives, collaboration projects with local and international art organizations, and other arts management services.

For more information about BIPAM, please visit: https://www.bipam.org/

## Panelist



**Wu Wei Wei**

វ៉េវ៉េ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកល្ខោននៅ សាកលវិទ្យាល័យជាតិសិល្បៈតៃប៉ិ ។ សព្វថ្ងៃ គាត់គឺជាសាស្ត្រាចារ្យពាក់កណ្តាលម៉ោង (assistant professor) នៅក្នុងដេប៉ាតឺម៉ង់សិល្បទស្សនីយភាពនៃសាកលវិទ្យាល័យបទដ្ឋានជាតិតៃវ៉ាន់ ហើយក៏ជាគ្រូបង្រៀន (lecturer) ប្រចាំនៅដេប៉ាតឺម៉ង់គ្រប់គ្រងសិល្បៈផ្នែកសិក្សាតន្ត្រីក័ងចូវស៊ីងហៃ (Guangzhou Xing-hai) ផងដែរ ។ គាត់ធ្វើការនៅក្នុងប្រទេសចិនដីគោកផងនិងនៅតៃវ៉ាន់ផង ។ ក្រៅពីធ្វើការ គាត់នៅធ្វៀតធ្វើការនៅស្ថាប័នសប្បុរសធម៌មួយកន្លែងឈ្មោះថា មូលនិធិសិល្បៈយើងរួមគ្នា (We Art Together Foundation) ក្នុងតួនាទីជានាយិកាប្រតិបត្តិ ក្នុងបំណងជួយធ្វើឱ្យមនុស្សស្គាល់និងចងមិត្តភាពជាមួយគ្នាតាមរយៈសិល្បៈ ។

ចំពោះការចូលរួមជាលក្ខណៈអន្តរជាតិរបស់គាត់មានដូចជាការចូលរួមសម្តែងសម្រាប់ទស្សនីយភាពតៃវ៉ាន់នៅក្នុងមហោស្រពអាវីញ៉ុង (Avignon) លើកទី ២ ដល់ទី ៤ ក្នុងប្រទេសបារាំង,ការសម្តែងក្នុងមហោស្រពសិល្បៈស្រមៃរបស់បារាំង, និងការសម្តែងឱ្យសហព័ន្ធរបាំពិភពលោកក្នុងទីក្រុងអង់ហ្សេរស៍ (Angers) នៃប្រទេសបារាំង ។

គាត់បានដឹកនាំនិងដំឡើងស្នាដៃជាការច្រៀងគ្មានភ្លេងមួយឈ្មោះថា “កញ្ញាតៃវ៉ាន់ ២០១៤” ដោយត្រូវគេជ្រើសរើសយកទៅសម្តែង នៅក្នុងមហោស្រពសិល្បៈអន្តរជាតិសៀងហៃ។ស្នាដៃមួយទៀតដែលគាត់បានដឹកនាំគឺ “នៃនភាវ (Nan Piao)” ដែលគេបានជ្រើសរើសយកទៅសម្តែងនៅមហោស្រពសិល្បៈថាយនៃន២០១៥និងដឹកនាំស្នាដៃឱ្យកម្មវិធីទូរទស្សន៍សម្តែងជាភាគឆ្នាំ ២០១៧ លក្ខណៈជាចម្រៀងឈ្មោះថា “អ្នកក្រុងញូវយ៉ក” ដែលគេបានជ្រើសរើសយកទៅសម្តែងនៅមហោស្រពតន្ត្រីអន្តរជាតិឌែហ្គូ និងជ្រើសរើសឱ្យជាប់កម្មវិធីពានរង្វាន់ “Best Supporting Actor” នៅក្នុង មហោស្រពតន្ត្រីអន្តរជាតិឌែហ្គូ នៅប្រទេសកូរ៉េខាងត្បូង ។

នៅឆ្នាំ ២០១៨ ក្នុងគម្រោង “តន្ត្រីថារូ (Musical Taru)” មួយដែលផលិតរួមគ្នារវាងកូរ៉េនិងចិន គាត់មានតួនាទីជាអ្នកដឹកនាំស្នាដៃសម្តែងមួយដែលបង្ហាញពីវប្បធម៌អាស៊ីនិងចិន ដោយមានការចូលរួមសហការដំឡើងនិងដឹកនាំការសម្តែងតន្ត្រីផ្ទាល់ពីក្រុមតន្ត្រី Neoclassical Chamber Orchestra ត្រង់វគ្គ “ការតែងកំណាព្យល្អ គឺត្រូវស្វែងរកអារម្មណ៍ពិត (Building Poems, Chasing Poems)” ដែលគេយកទៅសម្តែងនៅរោងល្ខោនជាតិ ហើយគេក៏បានជ្រើសរើសយកទៅធ្វើជា កម្មវិធីសម្តែងជាភាគឬស៊េរីសម្រាប់ ថ្ងៃខួបនៃការបើកមជ្ឈមណ្ឌលកៅហ្សុងជាតិដើម្បីសិល្បៈ (ឧទ្យានវ៉េវូយីង) ក្នុងឆ្នាំ ២០១៩ ។

## Wu Wei Wei

Wu Weiwei, graduated from Taipei National University of Arts MA Theatre, she is currently the assistant professor in National Taiwan Normal University Department of Performing arts, also lecturer of Guangzhou Xing-hai Music Academy Arts Management department. She works on both Mainland China and Taiwan. She has another role to balance the work and charity, she is the current CEO of We ART Together Foundation, devoting to make people knowing each other and making friends through art.

For International participation includes performances in the Taiwan Pavilion of the 2nd to 4th Avignon Off in France, the French Imagination Art Festival, and the WDA in Angers, France.

She directed and choreographed Acapella's musical "Miss Taiwan 2014" was selected for the Shanghai International Arts Festival, another musical she directed "Nan Piao" was selected for the 2015 Tainan Arts Festival, and the 2017 TV series -style musical "The New Yorker" was selected for the Daegu International Musical Festival, was nominated for Best Supporting Actor in Daegu International Musical, South Korea.

In 2018, the Sino-Korea co-produced musical "Musical Taru" served as the director of the Asian Chinese version, and choreographed and directed with the Neoclassical Chamber Orchestra "Building Poems, Chasing Poems" was performed at the National Theater and was selected as a series of programs for the opening anniversary of National Kaohsiung Center for the Arts (Weiwuying) in 2019.

For more information about We ART Together Foundation, please visit:
https://www.facebook.com/share/1Pg46LHkTA/?mibextid=wwXIfr

## Moderator



**Suon Bun Rith**

លោកសួន ប៊ុនរិទ្ធ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យក្រុងឡុងដ៍ និងជាអតីតគរុនិស្សិតជំនាន់ទី១ (បរិញ្ញា+១) នៃមហាវិទ្យាល័យគរុកោសល្យ (បច្ចុប្បន្ន វិទ្យាស្ថានជាតិអប់រំ)។

លោកធ្លាប់ជាប្រតិបត្តិករសិល្បៈ និងជាអ្នកដឹកនាំមួយរូបលើវិស័យសិល្បៈទស្សនីយភាពនៅកម្ពុជា ក្នុងពេលជាងពីរទសវត្សរ៍ ដោយបានដើរតួនាទីសំខាន់ក្នុង ផ្នែកគ្រប់គ្រងសិល្បៈវប្បធម៌ នៅស្ថាប័នសិល្បៈនានាដូចជា អង្គការយូណេស្កូ, មជ្ឈមណ្ឌលវប្បធម៌បារាំង, អម្រឹតាសិល្បៈ, ហ្វារពន្លឺសិល្បៈ និងសិល្បៈខ្មែរអមតៈ ជាដើម។

បច្ចុប្បន្ន លោកជាទីប្រឹក្សាស្រាវជ្រាវ ផ្នែកសិល្បៈវប្បធម៌ និងការអប់រំ និងជានាយកប្រតិបត្តិ អង្គការសង្ឃឹមកុមារកម្ពុជា ដែលមានបេសកកម្មលើកកម្ពស់ និងការពារសិទ្ធិកុមារ នៅទីជនបទឱ្យទទួលបានការអប់រំ និងការអភិវឌ្ឍដ៏ពេញលេញ។

Suon, Bun Rith is a research and training consultant in the culture and education sectors, actively involved in arts education, adult education, lifelong learning, teacher training and school projects. He holds a BA in Khmer Literature from the Royal University of Phnom Penh and trained as a high school teacher in 1996. In 2016, he earned an MA from SOAS, University of London. Rith currently serves as the Executive Director of Sangkheum Kumar Kampuchea (SKK), a nonprofit organisation he co-founded in 2018 to empower children in remote rural communities by providing access to a well-rounded foundational education.

វគ្គបង្ហាញស្នាដៃរបាំដើម្បីទទួលបានមូលនិធិ៖
អ្នកដំឡើងស្នាដៃរបាំទាំងដប់រូប
បង្ហាញស្នាដៃដំឡើងថ្មីសាកល្បង
និងការឆ្លើយសំណួរពីគណៈកម្មការតំបន់ទាំងបីរូប

**Pitching Session:**
**10 Junior Choreographers Presenting**
**Newly Choreographed Works**
**Followed by Q&A Session**
**with Three Regional Jurors**

Participant



Chan Sopheap

## របាំសហសម័យ «ស និង ខ្មៅ»

នៅក្នុងរបាំនេះនឹងនិយាយអំពីបញ្ហាសង្គម គ្រួសារ ដោយមានការចងចាំមួយដក់ជាប់កាលពីកុមារភាពរបស់នាងខ្ញុំ សង្គមគ្រួសារដែលមានតែបញ្ហាជម្លោះរវាងប្តី ប្រពន្ធរហូតឈានដល់អំពើហិង្សា និងចាប់ផ្តើមបែងចែកខុសនិងត្រូវ សឬខ្មៅ រហូតធ្វើអោយក្មេងស្រីម្នាក់នេះដែលជារូបខ្ញុំផ្ទាល់ធ្លាក់ចូលទៅនៅក្នុងព្រឹត្តិការណ៍ដ៏អាប់អួរមួយ។

រឿងរ៉ាវទាំងអស់នេះបានផ្តល់ជារូបភាពនិងជាការចងចាំមួយដែលជំរុញអោយនាងខ្ញុំលើកឡើង ជារបាំ សនិងខ្មៅ ដែលចង់បង្ហាញថា សនៅតែជាស ខ្មៅនៅតែជាខ្មៅ។ ទោះបីជាស្នាដៃនេះប្រៀបប្រដូចទៅនឹងជម្លោះរវាងប្តីប្រពន្ធក៏ដោយប៉ុន្តែយើងបានដឹងហើយថាសនៅតែតំណាងអោយភាពល្អបរិសុទ្ធ និងមានពន្លឺ ចំណែកឯខ្មៅតំណាងអោយភាពខ្មៅស្រអាប់ ងងឹត ភាពគ្រោតគ្រាត។ មិនខុសអ្វីពីពាក្យស្លោកដែលលើកឡើងថា សនៅតែស អ្នកធ្វើល្អនៅតែល្អ អ្នកខុសគឺខុស នៅក្បែរបណ្ឌិត គឺបណ្ឌិត ។

## Contemporary Dance "Black and White"

This dance addresses a significant social issue: the family. It reflects memories from my childhood, where I witnessed only arguments between my parents, leading to domestic violence as they sought to prove each other right and wrong, black and white. This chaos drew me, as a young girl, into a dark and unsettling situation.

These experiences shaped my vision and inspired me to create a dance piece titled "Black and White." The work conveys the idea that black remains black and white remains white, even when darkness seems to overshadow the light. Although this piece is a metaphore to the domestic violence between husband and wife, we all know what white symbolizes goodness, purity, and brightness, while black represents gloom and darkness. As the saying goes, "White is still white; good people remain doing good things , those who do bad still do bad things, staying with a doctor will make you a doctor."

Participant



Chhun Baramey

## របាំសហសម័យ «សិលា»

គឺជាភាសាសំស្ក្រឹត និង បាលី មានន័យថាថ្ម គឺអង្គធាតុរឹងមានវត្តមាននៅក្នុងចក្រវាឡ ផ្សំពីល្បាយរួមបញ្ចូលគ្នា ហើយប្រើរយៈពេលរាប់ពាន់ឬរាប់លានឆ្នាំទើបអាចក្លាយជាថ្មបាន ក្នុងស្នាដៃនេះចង់ស្វែងបង្ហាញពីលក្ខណៈរបស់ថ្មរួមមាន ភាពគង់វង្ស យូរអង្វែង និងទម្ងន់ដ៏ធ្ងន់របស់ថ្មសិលា។

ដោយហេតុតែយល់ឃើញយុវជនសព្វថ្ងៃ មានគំនិតគិតមិនសូវបានវែងឆ្ងាយ គ្មានភាពអំណត់ ឆាប់បាក់ស្បាតចុះចាញ់ និងឧបសគ្គជីវិត ទើបខ្ញុំសម្រេចជ្រើសយកគំនិតនេះឡើងមក ហើយសរសេរជាស្នាដៃដំឡើងទស្សនីយភាព របាំសហសម័យសម្តែងទោលមាន រយៈពេល៥នាទី ជាការចូលរួមពន្យល់ និងបង្ហាញជូនចំពោះអ្នកដែលកំពុងប្រឈម ឬកំពុងជួបនឹងវិបត្តិផ្លូវចិត្តក្នុងមជ្ឈឹមវ័យជាវ័យដែលត្រូវតែបង្ហាញពីសក្តានុពលរបស់ខ្លួនទៅសង្គមមនុស្ស ជាវ័យដែលគួរយល់ដឹងពីបំណិនជីវិត ហើយរឹងមាំមានចិត្តធ្ងន់ធន់ ប្រៀបនឹងថ្មសិលា ដែលមិនងាយចុះញ៉មនឹងឧបសគ្គទោះព្យុះភ្លៀងខ្យល់និងនៅតែរក្សាលំនឹងគោលជំហរអំណត់អត់ធន់ជានិច្ចជាកាលប្រកបដោយភាយោភាព។

## Contemporary Dance "Siḷā"

is a term derived from Sanskrit and Pali, meaning "stone." It refers to a solid entity that has formed in the universe from a combination of various substances over the course of thousands or millions of years. This work explores the characteristics of Siḷā, highlighting its consistency, durability, and substantial weight.

Recognizing that today's youth often lack long-term thinking, patience, and resilience and tend to succumb to life's challenges.
I decided to transform this concept into a 5-minute solo contemporary dance, aiming to shed light on the struggles experienced by individuals encountering a midlife mental crisis—an age when one is expected to harness their potential, develop life skills, and embody strength and resilience. Like Siḷā, which remains steadfast amid storms and adversity, this dance seeks to illustrate the importance of maintaining a calm and patient demeanor during times of significant responsibility.

## Participant



Dy Puthik

## របាំសហសម័យ «ផ្ទះ?»

គឺជាស្នាដៃរបាំដកពិសោធមួយ ដែលឆ្លុះបញ្ចាំងអំពីការប៉ះទង្គិចផ្លូវចិត្ត សេចក្តីស្រឡាញ់ និងដំណើរការនៃការព្យាបាលតាមរយៈចលនានិងការនិទានរឿង។ ស្នាដៃនេះលាតត្រដាងអំពីសាច់រឿងដែលបានលាក់ទុករបស់បុរសម្នាក់អំពីការប្រឈមមុខនឹងការប៉ះទង្គិចផ្លូវចិត្តរបស់គាត់នាពេលកន្លងមក ដោយការត្រលប់ទៅកាន់កន្លែងដ៏សុខស្រួលរបស់គាត់វិញនោះគឺ បន្ទប់គេង។

ដោយសារខ្លួនគឺជាក្មេងម្នាក់ទទួលបានការចិញ្ចឹមបីបាច់ពីឪពុកម្តាយដែលជាអ្នករួចផុតជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ការប៉ះទង្គិចផ្លូវចិត្តដោយសារសង្គ្រាមក៏បានក្លាយជាវិបត្តិផ្លូវចិត្តឆ្លងតជំនាន់ ទោះបីជាគាត់មិនបានឆ្លងកាត់សង្គ្រាមនោះក៏ដោយ។ នៅពេលធំឡើងគ្រួសាររបស់គាត់មិនសូវមានភាពជិតស្និទ្ធឡើយនេះក៏ដោយសារស្រមោលនៃការរត់គេចពីសេចក្តីស្លាប់នោះបានគ្របដណ្តប់លើអ្វីៗគ្រប់យ៉ាងក្នុងគ្រួសារ។ ភាពស្និទ្ធស្នាលពិតជាកម្រកើតមានណាស់នៅក្នុងគ្រួសារ។វាមានអារម្មណ៍ប្រៀបដូចជាការរស់នៅខាងក្នុងគុកឥតជញ្ជាំងដែលកើតពីវិបត្តិផ្លូវចិត្ត សេចក្តីស្ងាត់ស្ងៀម និងវិបត្តិអត្តសញ្ញាណ ដែលគុកនេះហើយបានមករឹតត្បិតគាត់ទាំងផ្លូវកាយនិងផ្លូវចិត្តរារាំងគាត់មិនឱ្យបញ្ចេញឬធ្វើអ្វីដែលខ្លួនចង់ធ្វើ។ ចំពោះបុរសឯកាម្នាក់នេះ គ្រែគេងរបស់គាត់មិនត្រឹមជាវត្ថុធម្មតាមួយប៉ុណ្ណោះនោះទេ ប៉ុន្តែវាជាកន្លែងដែលគាត់មានអារម្មណ៍ថាសុខស្រួល និងសុវត្ថិភាពបំផុតសម្រាប់ខ្លួនគាត់។ នេះហើយជាផ្ទះពិតប្រាកដរបស់គាត់ពីព្រោះថាផ្ទះមិនមែនគ្រាន់តែជាកន្លែងមួយប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាដំណើរការនៃការស្វែងរក ជាអារម្មណ៍ និងជាទំនាក់ទំនងផ្លូវចិត្តរបស់ខ្លួន។

យ៉ាងណាក៏ដោយពេលវេលាដ៏ល្អទាំងនោះមិនអាចនៅគង់វង់ស្ថិតស្ថេរបានឡើយ។អ្វីៗដែលបានកើតឡើងក៏រលាយទៅវិញបន្តិចម្តងៗ។ នៅពេលគាត់ព្យាយាមសម្រាក រាងកាយរបស់គាត់ក៏ចាប់ផ្តើមនឹកគិតដល់វិបត្តិដែលនៅត្របាញ់ជាប់នឹងខ្លួនគាត់ ដូចជា ភាពភ័យខ្លាចក្នុងចិត្ត ភាពស្ងាត់ស្ងៀមរបស់ឪពុកម្តាយគាត់ និងភាពស្រពេចស្រពិលនៃការធំដឹងក្តីឡើងជាមនុស្សស្រឡាញ់ភេទដូចគ្នានៅក្នុងផ្ទះដែលគេពិបាកនឹងទទួលស្គាល់គាត់។ គ្រែគេងក៏ក្លាយជាកន្លែងសុបិនដ៏អាក្រក់។ ដំណេកដែលធ្លាប់ជាកន្លែងមួយមានសុវត្ថិភាព ពេលនេះវាបានក្លាយទៅជាទ្វារដែលបើកទទួលយកអ្វីគ្រប់យ៉ាងដែលគាត់ព្យាយាមបំភ្លេចឱ្យមកវិញ។ គាត់ចាប់ផ្តើមរៀនប្រឈមមុខនឹងបញ្ហាទាំងនោះ ហើយនៅទីបំផុតគាត់ក៏ទទួលស្គាល់វត្តមានរបស់វា។ប្រហែលនេះក៏អាចជាវិធីសាស្ត្រនៃការព្យាបាលរបស់គាត់ដែរ ។

Dy Puthik

គំនិតនៃស្នាដៃ“ផ្ទះ?”ផ្តោតលើភាពលំបាកផ្នែកខាងក្នុងដោយសារវិបត្តិតជំនាន់នៃការប៉ះទង្គិចផ្លូវចិត្តនិងវិធីព្យាបាលដ៏ស្ងប់ស្ងាត់។ ការសម្តែងនេះបញ្ចូលគ្នារវាងក្បាច់សហសម័យនិងក្បាច់ដ៏ប្រណីតនៃរបាំក្បាច់បុរាណខ្មែរ។ កិច្ចសន្ទនាគ្នានឹងធ្វើឡើងក្នុងការសម្តែងនេះ ដើម្បីឈ្វេងយល់ឱ្យបានស៊ីជម្រៅលើបញ្ហាវិបត្តិផ្លូវចិត្ត ក៏ដូចជាដើម្បីពន្យល់បន្ថែមអំពីទិដ្ឋភាពជុំវិញសាច់រឿង។សំឡេងតន្ត្រីបែបពិសោធដែលបានថតទុកលាយជាមួយសំឡេងក្នុងជីវិតប្រចាំថ្ងៃនឹងជួយធ្វើឱ្យស្នាដៃនេះកាន់តែមានទំនាក់ទំនងស៊ីជម្រៅជាមួយទស្សនិកជន។វង់ភ្លេងពិណពាទ្យត្រូវបានប្រគំហើយវង់ភ្លេងនេះទុកដូចជាស្ពានភ្ជាប់រវាងប្រពៃណីបុរាណទៅនឹងភាពទំនើប ដើម្បីជំរុញសិល្បៈបុរាណឱ្យទៅដល់កម្ពស់ថ្មីមួយ។

## Contemporary Dance "Home? "

is an experimental dance that explores the complexity of trauma, love, and the process of healing through movement and storytelling. This piece tells an unspoken story of a young adult gay confronting his bottled-up traumas by returning to his comfort place, his bedroom.

As a child raised by parents who survived the Khmer Rouge genocide, generational trauma became an inheritance from a war he wasn't even part of. Growing up, his parents weren't affectionate with each other or with him, as the instinct to survive overshadowed everything else in the household. Intimacy was scarce. It felt like living inside an invisible box, one shaped by trauma, silence, and identity, that constrained him physically and emotionally, keeping him from expressing himself or doing what he truly wanted. To this lonely man, his bed is not just an object. It's where he can be his most vulnerable self. This is a home within a home, because a home is not just a place, but also a process, a feeling, and a form of personal spirituality.

But like all good moments, it doesn't last. What starts as stillness slowly turns into discomfort. As he tries to rest, his body begins to remember an entanglement of unspoken fears, his parents' silence, and the blurriness of growing up queer in a home that never fully accepted him. The bed becomes a place of nightmares. Sleep, once a safe space, now opens the door to everything he tried to forget. He starts to face these memories, not to fix them, but to finally see them for what they are. Perhaps, this is also his way of Healing.

The concept of Home? centers on the internal struggles of inherited trauma and the quiet journey toward healing. The performance draws from contemporary movement and the refined gestures of Khmer classical dance. Spoken dialogue will be included to deepen the emotional weight and clarify the layers of the story. Pre-recorded experimental music, blended with everyday sounds, will help make the piece feel more relatable to the audiences. The Pin Peat ensemble is used as a bridge between tradition and modernity, grounding the performance in cultural memory while pushing to a new height.

Participant



Kim Socheat

## របាំសហសម័យ «ទំនាក់ទំនង»

គឺជារឿងសំខាន់ធំមួយនៅក្នុងបរិយាបន្នសង្គមកម្ពុជា។ ស្នាដៃនេះបង្ហាញពីសាច់ពិតរបស់សិល្បករដែលមានពិការភាពម្នាក់ ដែលបានជួបនូវរឿងរ៉ាវជាច្រើនក្នុងឆាកជីវិតរបស់គាត់។ តាមរយៈស្នាដៃនេះ គាត់សូមឆ្លុះបញ្ចាំងអំពីការរើសអើងទៅលើជនមានពិការភាព និងការបាត់បង់ទំនាក់ទំនងរបស់គាត់ជាមួយនឹងមនុស្សក្នុងសង្គម។

កាលពីក្មេង សុជាតិធ្លាប់លេងល្បែងកំសាន្តមួយ គឺទំនាក់ទំនងគ្នាដោយប្រើកំប៉ុងនិងខ្សែ។នោះជាប្រភពនៃក្ដីរីករាយដ៏ស្រស់បំព្រងមួយរបស់គាត់កាលពីនៅក្មេង។ តាមរយៈអនុស្សាវរីយមួយនេះសុជាតិបានរកឃើញនូវគំនិតសម្រាប់ការដំឡើងរបាំសហសម័យមួយអំពីទំនាក់ទំនង។ប៉ុន្តែនៅក្នុងជីវិតជាក់ស្ដែងការព្យាយាមកសាងទំនាក់ទំនងជាមួយមនុស្សក្នុងសង្គមតែងធ្វើឱ្យគាត់កាន់តែមានអារម្មណ៍បាក់ទឹកចិត្ត និងអស់សង្ឃឹម។ អស់រយៈពេលជាច្រើនឆ្នាំកន្លងផុតទៅសុជាតិក៏បានកែប្រែចិត្តគំនិតបើកចិត្តរៀនអ្វីៗដែលថ្មីពីមនុស្សជុំវិញខ្លួន។ ជាភ័ព្វសំណាងល្អ គាត់ក៏បានជួបមិត្តល្អៗជាច្រើននៅក្នុងវិស័យសិល្បៈ ដែលតែងតែគាំទ្រ និងលើកទឹកចិត្តខ្លួនឱ្យព្យាយាមតស៊ូទៅមុខទៀត ដើម្បីចាប់នូវក្ដីស្រមៃរបស់ខ្លួន។

នៅក្នុងស្ថានភាពពេលនេះ តើសុជាតិគិតយ៉ាងណាចំពោះទំនាក់ទំនងមួយនេះ?

## Contemporary Dance "Relationship"

Tum Nak Tum Nong highlights critical issues in Cambodian society. It tells the true story of an artist living with disability, facing the numerous challenges. Through his work, Socheat aims to expose the discrimination against individuals living with disability and the resulting detachment from society.

In his young age, Socheat played a game involving communication with others via cans and string. That was the wellspring of his youthful happiness. This memory sparked an idea for a contemporary dance about relationships. However, in reality, the efforts to connect with others in society left Socheat feeling even more depress and hopeless. After many years, Socheat's thinking evloved, and he opened himself to learn from others. His luck in the arts led him to a circle of supportive friends who fueled his ambition and encouraged him to chase his dreams.

What does Socheat think about this relationship in this context?

## Participant



Pum Molyta

## របាំសហសម័យ «ស្រមោល»

ចង់បង្ហាញពីអតីតកាលមិនល្អរបស់តួអង្គស្រីម្នាក់ដែលជាមនុស្សពុំសូវមានទំនាក់ទំនងល្អក្នុងសង្គមមិនមានភាពជឿជាក់ មិនក្លាហាន ប្រៀបជាមនុស្សស្ងៀមស្ងាត់ ដែលជាហេតុជំរុញឱ្យតួអង្គនាពេលបច្ចុប្បន្ន ត្រូវតស៊ូប្រឆាំងនឹងស្រមោលអតីតកាលមិនល្អរបស់ខ្លួន ដើម្បី រកច្រកចេញពីភាពអវិជ្ជមាន ឆ្ពោះទៅរកភាពវិជ្ជមាន ដែលជាប្រភពនៃក្តីសង្ឃឹមនៃអនាគតកាលដ៏ត្រចះត្រចង់។ ជាផ្នែកមួយនៅក្នុងរបាំនេះ ខ្លួនខ្ញុំផ្ទាល់ជាមនុស្សម្នាក់មិនសូវចេះនិយាយមានភាពលំបាកក្នុងការប្រាស័យទាក់ទងជាមួយមនុស្សនៅក្នុងសង្គម។

ស្រមោល នឹងឆ្លុះបញ្ចាំងទៅលើដំណើររឿងរ៉ាវរបស់តួអង្គម្នាក់ដែលជួបប្រទះនឹងលំបាកជាមួយនឹងការប្រាស្រ័យទាក់ទង និងការសម្រេចចិត្តរបស់នាងក្នុងការដើរចេញពីអតីតកាលហើយស្វែងរកនូវក្តីសង្ឃឹមថ្មីសម្រាប់អនាគត។

## Contemporary Dance "Shadow"

The dance illustrates the troubled past of a female protagonist who struggles with her societal rejection, lacking confidence and bravery, much like someone who remains silent. This is why the current protagonist must confront the shadows of her difficult past to transition from negativity to positivity, ultimately seeking the wellspring of love that symbolizes a bright future. In this performance, I embody the quiet person who faces challenges in connecting and building relationships with others in society.

The narrative will depict the journey of a protagonist who grapples with difficulties in her social relationships as she confronts the decision to leave her past behind and pursue new hopes for the future.

Participant



Rong Thyrossika

## របាំសហសម័យ «សំពះ»

គឺជារបាំសហសម័យថ្មីមួយដែលមានអ្នកសម្តែងចំនួន ៥ នាក់ មានរយៈពេល ៣នាទី ១៥ វិនាទី ។

ខ្ញុំបង្កើតស្នាដៃនេះឡើង ព្រោះខ្ញុំចង់អោយគេស្គាល់ និងយល់ដឹងឱ្យកាន់តែច្បាស់ពីរបៀបនៃការសំពះ។វាជាសញ្ញានៃការគោរពសំខាន់មួយក្នុងវប្បធម៌ខ្មែរ ដែលជាទម្រង់នៃការស្វាគមន៍ការអបអរសាទរការសូមអភ័យទោសការថ្លែងអំណរគុណវាបង្ហាញពីសុជីវធម៌ និងឥរិយាបថដ៏សមរម្យ។ វិធីសំពះគឺយើងយកដៃទាំងពីរដាក់ផ្គុំគ្នាដូចជាទម្រង់ក្រពុំឈូក ហើយក៏អាចដាក់ទម្រង់ដៃនៅកម្រិតខុសៗគ្នាផង ដោយផ្អែកលើអាយុឋានៈឬស្ថានភាពរបស់អ្នកដែលយើងកំពុងសំពះ។

ជាទូទៅអ្នកធ្លាប់បានឃើញការសំពះ រឺ ជម្រាបសួរ (hello) នៅប្រទេសអាស៊ានផ្សេងៗគ្នា អ្នកគិតថា ការសំពះ រឺ ជម្រាបសួរវាជារឿងធម្មតា។ ប៉ុន្តែសម្រាប់ខ្ញុំវាមានលក្ខណៈពិសេស ព្រោះវាបង្ហាញពីអាកប្បកិរិយាគួរសមនិងប្រកបដោយគុណធម៌ ឥរិយាបទសមរម្យ ត្រឹមត្រូវក្នុងការប្រាស្រ័យទាក់ទងគ្នាដែលសបញ្ជាក់ពីមូលដ្ឋានលើវប្បធម៌ និងតម្លៃសីលធម៌របស់បុគ្គលម្នាក់ៗ។

## Contemporary Dance "Sampeh"

Sampeh is a new contemporary dance performed by 5 dancers, lasting 3 minutes and 15 seconds.

I choreographed it with the aim of making the Sampeh (Khmer greeting) performance more widely recognized and appreciated. It serves as an important symbol in Khmer culture, representing hospitality, enthusiasm, apologies, and gratitude. It reflects moral values and respectful conduct. To perform the Sampeh, bring your hands and fingertips together in the shape of an unopened lotus bud. The position of your hands should be placed at different levels depending on the age, class, and status of the person you are showing respect to.

Overall, the sampeh, or greeting, can be observed in various forms across ASEAN countries. Although it may appear simple to some, I believe it embodies distinctive and unique qualities that reflect polite attitudes, virtues, and proper behavior, highlighting the foundational culture and moral values of individuals.

Participant



Sim Dollar

## របាំសហសម័យ «នរណាក្នុងបន្ទប់អ្នក»

ប្រអប់គំនិត គឺជាលំហរទទេស្អាតមួយដែលគ្មានអ្វីទាល់តែសោះ វាគឺជាអាថ៌កំបាំងមួយដែលកប់ជ្រៅនៃជំរៅចិត្តរបស់មនុស្សម្នាក់ៗ ។ ប្រអប់គំនិតក៏តែងតែបើកលំហូរដើម្បីអោយ រឿងជាច្រើនចូលមកក្នុងប្រអប់គំនិតនៃបន្ទប់របស់យើងផងដែរ មានគំនិតវិជ្ជមាន និងអវិជ្ជមាន។ នៅក្នុងនោះប្រអប់បន្ទប់របស់យើងម្នាក់ៗ គឺមានទ្វារបើកចូលទៅខាងក្នុងបន្ទប់ក៏ពិតមែន តែក្នុងប្រអប់បន្ទប់នៃគំនិតរបស់យើងគឺគ្មានច្រកទ្វារក្រោយសម្រាប់អោយយើងរំដោះរឿងមិនល្អដែលបានចូលមកក្នុងជីវិតរបស់យើងចេញនោះទេ បើទោះបីជាពេលវេលាកន្លងផុតទៅយូរប៉ុណ្ណាក៏យើងនៅតែមានការចងចាំពីរឿងមិនល្អមនុស្សមិនល្អ ដែលធ្លាប់ធ្វើទង្វើមិនល្អមកកាន់យើង។

«ដូចនេះ តើយើងគួរធ្វើដូចម្ដេចដើម្បីរក្សាការពារតុល្យភាពប្រអប់របស់យើងអោយល្អបាននោះ ?»

## Contemporary Dance "Who's in your room"

A concept box is an empty space, a mystery that resonates deeply within the human heart. It unlocks a flow of a multitude of stories – both positive and negative – to flow into the "room" of our minds.

Inside, each of our individual rooms has a door for entry, but there's no back door for us to escape through or to let go of the negativity in our lives. Even after so much time has passed, we still carry the memories of the bad experiences and the people who have wronged us.

"So, how can we keep our boxes in a healthy balance?"

Participant



Soy Chanborey

## របាំសហសម័យ «ប៉ាក់ឌិន»

រំលេចអំពីដំណើររឿងរ៉ាវរបស់សិល្បករ តាមរយៈការរាំរបាំសហសម័យដែលប្រកបដោយភាពប៉ិនប្រសព្វ និងច្នៃប្រតិដ្ឋ ។ តាមរយៈចលនារបាំនៅក្នុងស្នាដៃនេះ បូរី នឹងលាតត្រដាងពីរឿងរ៉ាវរបស់ជីវិតសិល្បករដែលព្យាយាមតស៊ូនិងប្រឹងជំនះរាល់ឧបសគ្គនានាដើម្បីឈរជើងនៅលើវិថីសិល្បៈ។ នៅពេលវេលាចេះតែរំកិលទៅមុខ វ័យរបស់សិល្បករក៏កាន់តែចាស់ ហើយគាត់ក៏បានបាត់បង់ឱកាសសម្តែងជាបន្តបន្ទាប់។ ប៉ុន្តែការណ៍នេះ មិនអាចបញ្ឈប់សេចក្តីស្រឡាញ់ និងសេចក្តីសង្ឃឹមរបស់គាត់ចំពោះសិល្បៈឡើយ។ ផ្ទុយមកវិញ គាត់បែរជាស្វែងរកឱកាសរៀនបន្ថែមហើយអភិវឌ្ឍខ្លួនទៅជាអ្នកច្នៃសម្លៀកបំពាក់ដ៏ចំណានម្នាក់សម្រាប់របាំបុរាណខ្មែរ ដូចជា របាំបុរាណ និងល្ខោនខោលជាដើម។

តាមរយៈស្នាដៃនេះ បូរី ចង់ផ្តល់ជាសារក្រើនរម្លឹក និងលើកទឹកចិត្តដល់សិល្បករជំនាន់ក្រោយឱ្យមើលឃើញពីគុណតម្លៃ និងការលះបង់របស់សិល្បករចាស់ៗដែលពោរពេញដោយទេពកោសល្យសិល្បៈ ហើយនៅតែតស៊ូធ្វើការដោយអត់ធ្មត់អស់ពីកម្លាំងកាយចិត្ត ដើម្បីលើកស្ទួយ និងបណ្តុះគ្រាប់ពូជថ្មីក្នុងវិស័យសិល្បៈវប្បធម៌កម្ពុជា។

## Contemporary Dance "Pak Din"

A contemporary dance solo, Pak Din—meaning "Fine Embroidery" —portrays the journey of an artist whose life is woven with creativity, resilience, and deep devotion to the arts. Through movement, Borey tells the story of an artist navigating a path filled with perseverance and passion, facing the challenges of sustaining an artistic career over time. As opportunities to perform fade with age, the artist's love for the arts remains undiminished. Instead of retreating, they seek further training to become a skilled costume designer for Khmer classical dances, including mask dance and beyond.

With this piece, Borey pays tribute to the older generation of artists—those who continue to give tirelessly despite physical and emotional challenges. Pak Din is a call to the next generation to honor these quiet heroes, to remember their contributions, and to carry forward the legacy they have so beautifully crafted in Cambodian arts.

Participant



Vong Vannak

## របាំសហសម័យ «របាំង»

ជាស្នាដៃរបាំសហសម័យទោលដែលមានរយៈពេល៣នាទីកន្លះ ដោយស្នាដៃនេះឆ្លុះបញ្ចាំងអំពីរឿងរ៉ាវសម្ងាត់របស់តួអង្គម្នាក់ដែលមិនអាចបញ្ចេញអារម្មណ៍ពិតប្រាកដរបស់ខ្លួនមកខាងក្រៅបាន។ ឆ្លងកាត់នូវបទពិសោធនៃយុវភាពផ្ទាល់ខ្លួនបានញ៉ាំងចិត្តខ្ញុំឱ្យបង្កើតស្នាដៃរបាំនេះឱ្យលេចជារូបរាងឡើង។ តាំងពីកុមារភាពមកម្លេះ នៅពេលដែលខ្ញុំជួបប្រទះនូវបញ្ហាអ្វីមួយ ខ្ញុំតែងតែលាក់បាំងវានៅក្នុងចិត្តជានិច្ចហើយខ្ញុំតែងតែព្យាយាមរកដំណោះស្រាយបញ្ហានោះដោយស្ងៀមស្ងាត់បំផុត។ ប៉ុន្តែ នោះពិតជាពេលវេលាមួយដ៏លំបាកដែលខ្ញុំត្រូវស៊ូទ្រាំលាក់រឿងរ៉ាវទាំងអស់នោះនៅក្នុងចិត្ត។ជាក់ស្តែងខ្ញុំពិតជាចង់ទម្លាយរឿងនោះចេញមកក្រៅ ប៉ុន្តែវាហាក់មានរនាំងអ្វីម៉្យាងមករារាំងការគិត និងចេតនារបស់ខ្ញុំ។ ភាពភ័យខ្លាច គ្មានទំនុកចិត្ត ការព្រួយបារម្ភនិងភាពអសកម្មនៃទំនាក់ទំនងស្រាប់តែគ្របដណ្តប់ចិត្តខ្ញុំហើយធ្វើឱ្យរាងកាយនិងខួរក្បាលរបស់ខ្ញុំជាប់គាំង។ ស្របពេលជាមួយគ្នានោះ រូបភាពមិនច្បាស់លាស់ជាច្រើនបានសណ្ឋិតនៅក្នុងខួរក្បាលខ្ញុំ។ គ្រានោះ ខ្ញុំហាក់ដូចជាបាត់បង់នូវស្មារតីនិងភាពជាខ្លួនឯងខណៈពេលដែលខ្ញុំព្យាយាមស្វែងរកច្រកចេញនៃបញ្ហាដ៏ចាក់ស្រេះនេះ។ របាំនេះនឹងក្លាយជាសារមួយជូនដល់ទស្សនិកជន ដើម្បីត្រិះរិះពិចារណា ថាតើយើងគួរធ្វើបែបណាប្រសិនបើយើងធ្លាក់ចូលស្ថានភាពបែបនេះ?

## Contemporary Dance "A Barrier"

is a 3.5-minute contemporary dance solo depicting a character unable to express their true feelings. His own experiences in youth inspired him to choreograph this dance. Since childhood, I'd always hide my problems and try to solve them alone, which made it incredibly difficult to carry them all inside.
I definitely want to bring those issues to light, but there appeared to be a barrier hindering my thoughts and intentions. Fear, lack of confidence, concern, and communication inaction likely left my body and brain firmly stuck.

Meanwhile, a flood of hazy images filled my mind. I lost my spirit and sense of self as I struggled to resolve these complex problems.

This dance will prompt audiences to contemplate: How should we respond if we find ourselves in such a predicament?

**Participant**



**Yean Chhenghak**

## របាំសហសម័យ «ខុសគ្នា តែដូចគ្នា»

ជាស្នាដៃសម្ដែងជាដៃគូរ ដែលសិល្បករ យាន ឆេងហាក់ បានសហការជាមួយនាដកា ហ្សាលីន ចន្ទសុមនា បង្កើតឡើងក្នុងគោលបំណងចង់រំលេចអំពីការស្វែងរកប្រភពដើមផ្ទាល់ខ្លួន ការចេះសម្របខ្លួនរកតុល្យភាព និងការកសាងភាពជឿជាក់លើខ្លួនឯង។ ស្នាដៃនេះនឹងលាតត្រដាងនូវដំណើរសាច់រឿងដោយប្រើចលនាដងខ្លួន និងការបង្កើតមនោសញ្ចេតនា ដែលមើលទៅហាក់ដូចជាអង្គធាតុរាវដែលហូរ ស្ងប់ ហើយពុះកញ្ជ្រោលឡើងមកវិញមិនឈប់មិនឈរ។

តួអង្គទាំងពីរនេះនឹងបង្ហាញ នូវការប្រជែងរវាងឥទ្ធិពលទន់ខ្សោយនិងខ្លាំងក្លាដែលឥទ្ធិពលនេះអាចបង្កើតជាភាពចលាចលមួយនៅក្នុងសង្គម។ ដូច្នេះ តើតួអង្គទាំងពីរនេះអាចរកចំណុចប្រសព្វមួយ ដើម្បីឈ្វេងយល់ពីគ្នា និងរកភាពសុខដុមរស់ជាមួយគ្នាដោយរបៀបណា?

## Contemporary Dance "Different, but the same"

is a duet created collaboratively by Yean Chhenghak and Zaline Chansomono. This piece aims to explore their individual backgrounds, the journey of self-adaptation for balance, and the development of self-confidence. This piece narrates a story through dynamic body movements, creating a romantic atmosphere that flows like a tranquil stream and bubbles back up with intensity.

These two characters will illustrate the challenge between weak and strong influences, which can lead to societal chaos. So, how can these two characters find a common ground to understand one another and achieve harmony?

## Mentor



**Fouad Boussouf**

For Fouad Boussouf, dance is pure impulse, momentum, movement. These words also define his artistic journey, driven by his innate curiosity and desire to escape –. His early years in Morocco, in an isolated rural village of monastic simplicity – were his first artistic inspiration. His family moved to France when he was seven; here he learned the culture and codes of this new universe, and began dancing hip hop to the cassette stylings of Prince and Michael Jackson. Dance became the instrument of his personal development and his growing awareness of the body. He trained at the Paris Cité Véron Academy, taught classes in street.dance, participated in several pieces in the Suresnes Cité Danse Festival and earned a DESS degree in social science, with a thesis on hip hop.

At the age of 27, after a long road trip around Australia, he founded his Compagnie Massala and in 2010 created his first group work, Déviations.(Detours). Ignoring all attempts at labeling, he built his own hybrid, contemporary dance vocabulary which featured hip hop dance in projects often inspired by his Mediterranean roots, as well as his interest in visual arts. Beginning in 2018, the popular success of his piece Näss. (Les.Gens) .(Nass.(People)), followed two years later by Oüm, an homage to Oum Kalthoum – introduced him to the international dance scene. Given his interest in pluridisciplinarity creation, he collaborated with the plastician Ugo Rondinone on the video installation Burn.to.shine (2022) and on Vïa (2023), a commissioned work from the Ballet du Grand Théâtre in Geneva. Since January 1, 2022, Boussouf, who was recently awarded the prestigious distinction of Chevalier des Arts et des Lettres – has been the artistic director of Le Phare – Centre chorégraphique national du Havre Normandie.

For more info about the mentor, please visit: https://lephare-ccn.fr/

## Mentor



**Emmanuèle Phuon**

Emmanuèle Phuon is a dancer, choreographer, and educator based in New York and Brussels. Phuon has performed internationally with the Elisa Monte Dance Company, Martha Clarke, Baryshnikov's White Oak Dance Project, and Yvonne Rainer. She teaches Rainer repertory and has helped set major exhibitions worldwide—notably in Japan, China, and Sweden. Her own choreographic work has been commissioned and presented at the Baryshnikov Arts Centre, New Haven's Festival of Arts and Ideas, Spoleto Dance Festival Charleston, Guggenheim Works and Process, Singapore Da:ns festival, Hong Kong International Dance Festival, Danspace Project in New York (NYT Critic's Pick), Kaatsbaan Cultural Center, the Hopkins Center for the Arts and the Quick Center for the Arts, among others. Ms. Phuon is the recipient of a Richard Porter Leach fellowship, a Baryshnikov Arts Center's Martha Duffy Memorial Fellowship, and a 2019 New York Public Library for the Performing Arts Dance Research Fellowship. She is on faculty at Montclair State University, NYU Tisch School of the Arts, and Yale University. She has authored "Postmodern Dance: Laboratory of Rupture," a chapter in  Milestones in Dance in the USA (Routledge 2022), "Cambodian Dance Diaspora," for the Winter 2023 issue of Dance Index (Eakins Press), and is currently collaborating with Yvonne Rainer on a book about dance pedagogy and improvisation. Emmanuele-phuon.com

For more info about the mentor, please visit: https://emmanuele-phuon.com/index.php/works/

## Institut français du Cambodge

Attached to the French Embassy in Cambodia, the French Institute of Cambodia (IFC) is responsible for promoting and disseminating the French language and culture, higher education and research, and fostering dialogue between Cambodian and French cultures. In this capacity, the Institute implements a range of initiatives, particularly in the fields of visual arts, debate, and expertise, as well as mobility programs, French language teaching, and educational resources, among others.

## Cambodian Living Arts (CLA)

Founded in 1998 with a mission to catalyze a vibrant arts sector, CLA initially focused on reviving and preserving traditional performing arts on the verge of disappearing. During that period, CLA supported master artists in passing their knowledge to over 300 students in various art forms across Cambodia.

By the 2010s, CLA shifted toward nurturing a new generation of young artists by offering scholarships, fellowships, fair-paying jobs through regular performance platform, professional development programs, and a five-year pilot arts education program in select public schools.

Since 2017, in response to limited resources for artists and cultural workers, CLA has provided small grants, creative skills workshops, and support for new works. Today, CLA supports artists and organizations across all art forms, with an emphasis on strengthening and developing the entire arts sector.

## Mekong Cultural Hub (MCH)

Mekong Cultural Hub (MCH)'s mission is to empower diverse cultural practitioners to bring to life their visions for an inclusive, sustainable Asia. Since 2018, we have connected more than 250 practitioners from the region for professional exchange, co-creation and collaboration.

MCH works with people whose own work is at the intersection of arts and society. We initiate projects and work on collaborations all around Asia. Our priority focus countries are Cambodia, Laos, Myanmar, Taiwan, Thailand and Vietnam.

CHAKTO AMBASSADE DE FRANCE AU CAMBODGE INSTITUT FRANÇAIS Cambodge CAMBODIAN LIVING ARTS MEKONG CULTURAL HUB